ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌអប់រំស្តែមកម្រិតសាលារៀន

គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ
កម្រិតមធ្យមសិក្សាទុតិយភូមិ ( STEP UP )

ខែមិថុនា ឆ្នាំ២០២៥

# មាតិកា


មាតិកា ..................... i
តារាង ..................... ii
រូប ..................... iii
បុព្វកថា ..................... iv
១-ទស្សនទាននៃការអប់រំស្ទែម ..................... 6
១.១-បរិបទសកល និងតំបន់នៃការអប់រំស្ទែម ..................... 6
១.២-បរិបទកម្ពុជា ..................... 8
១.៣-បច្ចុប្បន្នភាពការអប់រំស្ទែមនៅកម្ពុជា និងបញ្ហាប្រឈម ..................... 10
២-ក្របខណ្ឌការអប់រំស្ទែមនៅកម្ពុជា ..................... 10
២.១- គោលបំណងនៃការអប់រំស្ទែមនៅកម្ពុជា ..................... 10
២.២- គោលដៅនៃការអប់រំស្ទែមនៅកម្ពុជា ..................... 11
៣- ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ..................... 12
៣.១- គោលបំណង ..................... 12
៣.២- សមាសភាគ ..................... 12
៣.៣-កម្រិតអភិវឌ្ឍន៍របស់សាលារៀន ..................... 15
៣.៤-ជំហាននៃការអនុវត្ត និងកញ្ចប់ឧបករណ៍ស្ទែម ..................... 17
ជំហានទី១៖ ការបង្កើតគណៈកម្មការអនុវត្តសកម្មភាពអប់រំស្ទែម ..................... 18
ជំហានទី២៖ ការធ្វើស្វ័យវាយតម្លៃ និងការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ ..................... 19
ជំហានទី៣៖ ការពិនិត្យឡើងវិញ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL) និងការកំណត់គោលដៅ ..................... 20
ជំហានទី៤៖ ការអនុវត្តផែនការសកម្មភាពស្ទែម ..................... 22
ជំហានទី៥៖ ការត្រួតពិនិត្យវឌ្ឍនភាព និងការអនុវត្តឡើងវិញប្រចាំឆ្នាំ ..................... 22

# តារាង

តារាងទី 1៖ សេចក្ដីសង្ខេបក្របខណ្ឌអប់រំស្ទែមដែលមានស្រាប់ទូទាំងពិភពលោក........................................... 6
តារាងទី 2៖ សេចក្ដីសង្ខេបវិធីសាស្ត្រប្រើប្រាស់នៅក្នុងក្របខណ្ឌការអប់រំស្ទែមមានស្រាប់ទូទាំងពិភពលោក............... 7
តារាងទី 3៖ សេចក្ដីសង្ខេបសមាសភាគ សមាសភាគរង និងប្រធានបទនៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន......12
តារាងទី 4៖ សេចក្ដីពិពណ៌នាអំពីកម្រិតអភិវឌ្ឍន៍ទាំង៥......................................................................16
តារាងទី 5៖ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប(ODL)*......................................................................... 20
តារាងទី 6៖ សេចក្ដីសង្ខេបនៃកម្រិតអភិវឌ្ឍន៍សរុប(ODL) និងការកំណត់សមាសភាពខ្លាំងនិងខ្សោយ..................21
តារាងទី 7៖ ការប្រៀបធៀបកម្រិតអភិវឌ្ឍន៍របស់សមាសភាគនីមួយៗ រវាងដើមឆ្នាំនិងចុងឆ្នាំ .............................. 23
តារាងទី 8៖ ការតាមដានវឌ្ឍនភាពផ្អែកលើតម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) ដែលបានវាយតម្លៃជាច្រើនដង ........ 23

# រូប

រូបទី 1៖ កម្រិតអភិវឌ្ឍន៍របស់សាលារៀន.....15
រូបទី 2៖ ជំហានទាំង៥ នៃការអនុវត្តក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និងកញ្ចប់ឧបករណ៍ស្ទែម .....17
រូបទី 3៖ សេចក្ដីសង្ខេបនៃសមាជិក និងតួនាទីរបស់ក្រុមអនុវត្តសកម្មភាពស្ទែម.....18

# បុព្វកថា

កំណើនសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មទៅក្នុងសកលលោករបស់កម្ពុជា គឺពឹងផ្អែកលើកម្លាំងពលកម្មដែលបានត្រៀមខ្លួនរួចជាស្រេច មានគំនិតច្នៃប្រឌិត និងជំនាញបច្ចេកទេស។ ក្នុងបរិបទដែលកម្ពុជាប្ដេជ្ញាចិត្តប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើរតួយ៉ាងសំខាន់ក្នុងការកំណត់ភាពជោគជ័យនាពេលអនាគត។

ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងលើកកម្ពស់ការអប់រំស្ទែមនៅតាមសាលារៀន ជាពិសេសនៅតាមវិទ្យាល័យធនធាន និងសាលារៀនបណ្ដាញតាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP) និងគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP-II)។ ក្រសួង ក៏បានរៀបចំគោលនយោបាយស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅឆ្នាំ២០១៦។ បន្ថែមលើនេះ ក្រសួងបានអនុម័តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ដោយបានលើកឡើងពីការយកចិត្តទុកដាក់លើការពង្រឹង និងពង្រីកការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅកម្រិតមធ្យមសិក្សាផងដែរ។

ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ត្រូវបានរៀបចំឡើងដើម្បីផ្ដល់នូវវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងមានរចនាសម្ព័ន្ធច្បាស់លាស់ ក្នុងការបញ្ចូលការអប់រំស្ទែមនៅកម្រិតសាលារៀន តាមរយៈការកសាងសមត្ថភាព របស់សាលារៀនក្នុងការផ្ដល់ការអប់រំស្ទែម និងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងកម្រិតថ្នាក់ខ្ពស់ៗ និងកម្លាំងពលកម្មជំនាញខ្ពស់សម្រាប់ការអភិវឌ្ឍឧស្សាហកម្មរបស់ប្រទេស។ ក្របខណ្ឌនេះ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ព្រមទាំងស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ និងគោលនយោបាយស្ដីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ក្របខណ្ឌនេះមានគោលបំណងលើកកម្ពស់សមត្ថភាពសិស្ស និងអ្នកអប់រំទូទាំងប្រទេស តាមរយៈការផ្ដល់ឱ្យនូវមូលដ្ឋានគ្រឹះសម្រាប់ឧត្តមភាពនៃការសិក្សា ការគិតបែបត្រិះរិះពិចារណា និងការច្នៃប្រឌិតនៅក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ក្របខណ្ឌនេះ ចែកចេញជា ៥ សមាសភាគ រួមមាន លទ្ធផលការសិក្សារបស់សិស្ស ការបង្រៀននិងរៀន អភិបាលកិច្ចសាលារៀន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការចូលរួមរបស់សហគមន៍ ស្របតាមស្តង់ដាទាំង ៥របស់សាលារៀនគំរូ។ បន្ថែមលើនេះ ក្របខណ្ឌ ត្រូវបានរៀបចំឡើងជា ៥ កម្រិតអភិវឌ្ឍន៍ ដោយផ្អែកលើកម្រិតការអប់រំស្ទែមរបស់សាលារៀន។ សាលារៀនអាចធ្វើស្វ័យវាយតម្លៃអំពីស្ថានភាពការអប់រំស្ទែម និងឈ្វេងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ព្រមទាំងរៀបចំផែនការសកម្មភាពដើម្បីពង្រឹងការអប់រំល្អម។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រុមការងារបច្ចេកទេស និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំឯកសារដ៏មានសារៈសំខាន់នេះ។ ក្រសួងសូមឱ្យអ្នកពាក់ព័ន្ធទាំងអស់ អនុវត្តក្របខណ្ឌនេះ ដោយការទទួលខុសត្រូវ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# ១-ឧបត្ថម្ភនៃការអប់រំស្ទែម

## ១.១-បរិបទសកល និងតំបន់នៃការអប់រំស្ទែម

ការអប់រំស្ទែម ( STEM Education ) (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ) ដើរតួសំខាន់នៅក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេស តាមរយៈការបង្កើតកម្លាំងការងារប្រកបដោយសមត្ថភាព និងគុណភាពសម្រាប់ការច្នៃប្រឌិត និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗដែលមានឥទ្ធិពលលើវិស័យសេដ្ឋកិច្ច និងសង្គមជាតិនៅកម្រិតអន្តរជាតិ។ ផ្អែកលើការសិក្សាស្រាវជ្រាវបង្ហាញថា ប្រទេសជាច្រើនបានលើកទឹកចិត្តឱ្យអនុវត្តការអប់រំស្ទែម ជាផ្នែកមួយនៃការទទួលខុសត្រូវក្នុងការផ្តល់ឱកាសសម្រាប់យុវជន ក្នុងការត្រៀមខ្លួនសម្រាប់ការប្រកួតប្រជែងនៅលើផ្នែកបច្ចេកវិទ្យា និងវិស្វកម្ម។

ក្របខណ្ឌការអប់រំស្ទែមជាច្រើនត្រូវបានបង្កើតឡើងនៅទូទាំងពិភពលោក ដែលផ្តល់ការណែនាំ និងការគាំទ្រសម្រាប់សាលារៀន និងអាជ្ញាធរមូលដ្ឋាន និងមានតែមួយចំនួនប៉ុណ្ណោះនៃក្របខណ្ឌនេះដែលរួមបញ្ចូលវិធីសាស្ត្រពហុកម្រិត ឬកម្រិតអភិវឌ្ឍន៍។ ក្របខណ្ឌពហុកម្រិតទាំងនេះ ភាគច្រើនត្រូវបានបង្កើតឡើងនៅក្នុងសហរដ្ឋអាមេរិក ហើយត្រូវបានរៀបចំឡើងដើម្បីឱ្យស្របតាមស្តង់ដាអាមេរិក និងសមត្ថភាពសាលារៀននៅក្នុងប្រទេសផ្ទាល់។ ទោះបីជាឧទាហរណ៍ទាំងនេះ មិនអាចយកមកអនុវត្តដោយផ្ទាល់ក្នុងបរិបទកម្ពុជាក៏ដោយ ប៉ុន្តែអាចផ្តល់នូវការយល់ដឹងដ៏មានតម្លៃដើម្បីជួយកំណត់ជាគោលការណ៍អនុវត្តសម្រាប់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននៅកម្ពុជា។ តារាងទី១ ផ្តល់នូវសេចក្តីសង្ខេបនៃក្របខណ្ឌអប់រំស្ទែមដែលមានស្រាប់ ដែលត្រូវប្រើជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំក្របខណ្ឌការអប់រំស្ទែមកម្រិតសាលារៀនក្នុងឯកសារនេះ និងតារាងទី២បង្ហាញពីវិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងក្របខណ្ឌដែលមានស្រាប់លើចំណុចគួរឱ្យកត់សម្គាល់ចំនួនពីរ។

**តារាងទី 1៖ សេចក្តីសង្ខេបក្របខណ្ឌអប់រំស្ទែមដែលមានស្រាប់ទូទាំងពិភពលោក**

| តំបន់ | ឈ្មោះ/ប្រភេទឯកសារបោះពុម្ពផ្សាយ | រៀបចំ/និពន្ធដោយ |
|---|---|---|
| ពិភពលោក | STEM Education Framework[1] | Global STEM Alliance ( GSA )<br>A New York Academy of Sciences initiative |
| អឺរ៉ុប | The STE( A )M IT Framework[2] | European School net |
| អាស៊ី | Indonesia: Academic Review[3] | Universitas Negeri Yogyakarta, Indonesia |
| | Singapore: Academic Review[4] | National Institute of Education ( NIE ), Singapore |

[1] Global STEM Alliance, The New York Academy of Sciences (2016). STEM Education Framework Link

[2] Tasiopoulou et al., European Schoolnet (2022). European Integrated STEM Teaching Framework (The STE(A)M IT Framework), ISBN: 9789464595079 Link

[3] Arlinwibowo, J, (2020). The Types of STEM Education Implementation in Indonesia, Journal of Xi'an University of Architecture & Technology, 7(8), pg 606-613

[4] Tang Wee Teo (2019). STEM Education Landscape: The Case of Singapore, J. Phys.: Conf. Ser. 1340 012002 Link

| | | |
|---|---|---|
| | Thailand: Academic Review[5] | Curtain University, Australia & Ministry of Education, Thailand |
| អូស្ត្រាលី | STEM Framework[6] | Tasmanian Government, Department of Education |
| សហរដ្ឋអាមេរិក | Texas Education Agency[7] | Texas Education Agency, ( State Government ) |
| | Carnegie STEM Excellence Pathway[8] | Carnegie Science Centre, Pennsylvania |
| | STEM Immersion Guide[9] | Arizona STEM Network, Led by Science Foundation Arizona |
| | STEM School Study[10] | Outlier Research & Evaluation, University of Chicago |

**តារាងទី 2៖ សេចក្តីសង្ខេបវិធីសាស្ត្រប្រើប្រាស់នៅក្នុងក្របខណ្ឌការអប់រំស្ទែមមានស្រាប់ទូទាំងពិភពលោក**

| ឈ្មោះ | កម្រិតការអប់រំស្ទែមតិចសាស់ ( Texas STEM Education Framework )[11] | គន្លងឧត្តមភាពស្ទែម Carnegie ( Carnegie STEM Excellence Pathway )[12] |
|---|---|---|
| **គោលវិធី** | គំរូសាលារៀនត្រូវបានកំណត់ដោយការចូលរួមសកម្មភាពស្ទែមរបស់សិស្ស។ ( ការបង្កើនកម្មវិធីសិក្សាបន្ថែមដើម្បីប្រែក្លាយទៅជាកម្មវិធីសិក្សាស្ទែមបញ្ចូលគ្នា ) | ការបំពេញការងាររបស់សាលារៀនត្រូវបានវាយតម្លៃដោយផ្អែកលើសមាសភាគចំនួន៦។ ( សមាសភាគនីមួយៗ ត្រូវបានវាយតម្លៃដាច់ដោយឡែកពីគ្នា ) |

[5] Suriyabutr, A., (2021). Integrated STEM education in Thai secondary schools: challenge and addressing of challenges, J. Phys.: Conf. Ser. 1957 012025 Link
[6] Tasmanian Government, Department of Education (2017), STEM Framework Link
[7] Texas Education Agency (TEA), Texas STEM Framework, Link
[8] Carnegie Science Centre, Carnegie STEM Excellence Pathway Link
[9] Arizona STEM Network (2014). The STEM Immersion Guide Link
[10] Outlier Research & Evaluation, University of Chicago (2013). S3 STEM School Study, Link

[11] Texas Education Agency (TEA), Texas STEM Framework, Link
[12] Carnegie Science Centre, Carnegie STEM Excellence Pathway Link

| | | |
|---|---|---|
| **សមាសភាគស្ទែម** | 1. សមភាពនៃការសរសេរកម្មវិធី<br>2. វប្បធម៌ និងបរិយាកាសសាលារៀន<br>3. ការរៀបចំកម្មវិធី<br>4. ទិដ្ឋភាពនៃកម្មវិធីសិក្សា<br>5. ការចូលរួមរបស់អ្នកពាក់ព័ន្ធ<br>6. យុទ្ធសាស្ត្រទំនាក់ទំនង/ទីផ្សារ | 1. គុណវុឌ្ឍិគ្រូបង្រៀន<br>2. កម្មវិធីសិក្សា<br>3. ការបង្រៀន<br>4. វាយតម្លៃ និងការបង្ហាញពីជំនាញ<br>5. ការចូលរួមរបស់គ្រួសារ<br>6. ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ |
| **ចំនួនកម្រិត/ម៉ូឌែល** | មានគំរូសាលារៀនចំនួន ៤ | មានកម្រិតចំនួន ៥ តាមសមាសភាគនីមួយៗ |
| **កម្រិតអភិវឌ្ឍន៍** | i. ការឈ្វេងយល់ (Exploratory)<br>ii. ការចាប់ផ្ដើម (Introductory)<br>iii. ការអនុវត្តបានខ្លះ (Partial Immersion)<br>iv. ការអនុវត្តបានពេញលេញ (Full Immersion) | i. ការត្រៀមខ្លួនអនុវត្ត (Pre-emerging)<br>ii. ការចាប់ផ្ដើមអនុវត្ត (Emerging)<br>iii. កំពុងដំណើរការ (Progressing)<br>iv. ការរីកចម្រើន (Advancing)<br>v. ការនាំមុខ (Leading) |

## ១.២-បរិបទកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា បានប្ដេជ្ញាប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដូចបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលក្នុងនោះ មុំទី១នៃបញ្ចកោណទី១ បានសង្កត់ធ្ងន់ជាពិសេសលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ក្នុងន័យនេះ ការកសាងមូលធនមនុស្សឱ្យក្លាយជាឃ្លាំងសកលនៃចំណេះដឹង បានក្លាយជាអាទិភាពចម្បងក្នុងរបៀបវារៈនៃការអភិវឌ្ឍជាតិ។

នាពេលកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានប្រឹងប្រែងលើកកម្ពស់ការអប់រំស្ទែមនៅតាមសាលារៀនធនធាន និងសាលារៀនបណ្ដាញ តាមរយៈគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP) និងគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP-II) ដែលផ្ដល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំមធ្យមសិក្សាទុតិយភូមិ ក្រសួងបានរៀបចំគម្រោងថ្មីមួយទៀតដែលមានឈ្មោះថា គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (STEP UP)។ គំនិតផ្ដួចផ្ដើមនេះគឺជាការបន្តការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិរបស់ប្រទេសកម្ពុជា ដោយផ្ដោតជាក់លាក់លើការអប់រំស្ទែម។ គោលបំណងរួមនៃគម្រោង STEP UP គឺដោះស្រាយការកើនឡើងនៃតម្រូវការធនធានមនុស្សដែលមានគុណភាពខ្ពស់ និងជាធាតុផ្សំដ៏សំខាន់ក្នុងការទ្រទ្រង់សង្គម ឧស្សាហកម្ម បច្ចេកវិទ្យា និងសង្គមដែលផ្អែកលើការវិវឌ្ឍយ៉ាងឆាប់រហ័សរបស់កម្ពុជា។ បន្ថែមលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោល

នយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ( STEM ) នៅឆ្នាំ២០១៦។ គោលនយោបាយនេះ បានរំលេចនូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រសំខាន់ៗ ដែលយុទ្ធសាស្ត្រមួយក្នុងចំណោម៥ បានលើកឡើងអំពីការអភិវឌ្ឍគ្រឹះស្ថានសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ដើម្បីលើកកម្ពស់ការអប់រំស្ទែមនៅតាមសាលារៀនដែលមានសមត្ថភាពខុសៗគ្នា ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការរៀបចំក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនតាមរយៈគម្រោង STEP UP។ ការរៀបចំក្របខណ្ឌនេះគឺឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងស្របតាមគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននឹង៖

- សម្របតាមតម្រូវការរបស់កម្ពុជា
- ផ្តល់ការណែនាំសម្រាប់សាលារៀនដើម្បីអនុវត្តការអនុវត្តស្ទែមប្រកបដោយប្រសិទ្ធភាពនៅកម្រិតសាលារៀន
- កំណត់គោលដៅដែលអាចសម្រេចបាន និងការអនុវត្តជាប្រចាំ ដើម្បីជួយដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្ស គ្រួសារ និងសហគមន៍ ដើម្បីទទួលយកវិធីសាស្ត្ររួមមួយសម្រាប់ការអប់រំស្ទែម
- ផ្តល់មតិត្រឡប់មកក្រសួងអប់រំ យុវជន និងកីឡា អំពីកម្រិតនៃការអប់រំស្ទែមទូទាំងប្រទេស។

ឯកសារនេះផ្តល់នូវការពិពណ៌នាលម្អិតនៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និងពន្យល់ពីរបៀបដែលសាលារៀនអាចប្រើប្រាស់កញ្ចប់ឧបករណ៍ស្ទែមដែលភ្ជាប់មកជាមួយ ដើម្បីបង្កើនការអនុវត្តស្ទែម។

និយមន័យសម្រាប់ពាក្យទាក់ទងនឹងស្ទែមក្នុងវិស័យអប់រំមធ្យមសិក្សានៅកម្ពុជាក្នុងបរិបទនៃក្របខណ្ឌនេះ មានដូចខាងក្រោម៖

- ស្ទែម ( STEM ) គ្របដណ្តប់ដោយមុខវិជ្ជាទាំងបួននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- មុខវិជ្ជាស្ទែមសម្រាប់មធ្យមសិក្សាទុតិយភូមិមានមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា បច្ចេកវិទ្យា ( ICT ) និងផែនដីវិទ្យា
- ការអប់រំស្ទែមសម្រាប់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា សំដៅលើការពង្រឹងការបង្រៀន និងការរៀនមុខវិជ្ជាស្ទែមតាមរយៈការដាក់បញ្ចូលខ្លឹមសារសិក្សាទៅក្នុងជីវិតរស់នៅជាក់ស្តែង ការទទួលយកវិធីសាស្ត្របង្រៀនបែបទំនើប និងការលើកទឹកចិត្តនៃការរីកចម្រើនបន្តិចម្តងៗឆ្ពោះទៅរកវិធីសាស្ត្រអន្តរកម្មសិក្សា។ ចំណុចរួមនៃវិធីសាស្ត្រស្ទែមនេះ គឺជាសកម្មភាពដែលបណ្តុះបំណិនសតវត្សរ៍ទី២១ រួមទាំងសកម្មភាពផ្អែកលើគម្រោង សកម្មភាពផ្អែកលើបញ្ហា និងសកម្មភាពអនុវត្តផ្ទាល់ ដែលត្រូវបានពង្រឹងដោយបច្ចេកវិទ្យា ( ICT ) និងការបញ្ចូលគោលការណ៍សិល្បៈ ឬការរចនាតាមដែលសមស្រប
- ការអនុវត្តស្ទែមសម្រាប់មធ្យមសិក្សាទុតិយភូមិ គឺជាការអនុវត្តការបង្រៀន ឬសកម្មភាពសិក្សាណាមួយ ដែលស្របតាមវិធីសាស្ត្រអប់រំស្ទែមសម្រាប់មធ្យមសិក្សាទុតិយភូមិ រួមទាំងសកម្មភាពអនុវត្តជាក់ស្តែង ការពិសោធ

ការប្រើប្រាស់បច្ចេកវិទ្យា ការងារសហការឬជាក្រុម សកម្មភាពអន្តរកម្មសិក្សា សកម្មភាពផ្អែកលើគម្រោង សកម្មភាពផ្អែកលើបញ្ហា និងគម្រោងសហគមន៍ជាដើម។

### ១.៣-បច្ចុប្បន្នភាពការអប់រំស្ទែមនៅកម្ពុជា និងបញ្ហាប្រឈម

ការអប់រំស្ទែមនៅកម្ពុជានាពេលបច្ចុប្បន្ននេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍នានា ដែលភស្តុតាងនៃការយកចិត្តទុកដាក់រួមមាន៖

- រដ្ឋាភិបាលកម្ពុជាបានដាក់អាទិភាពលើការអប់រំស្ទែមនៅក្នុងមុំទី១ នៃបញ្ចកោណទី១ (ការអភិវឌ្ឍមូលធនមនុស្ស)
- ក្រសួងអប់រំ យុវជន និងកីឡា បញ្ចូលការអប់រំស្ទែមនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និង ២០២៤-២០២៨។ ក្រសួងបានណែនាំការអប់រំស្ទែមជាផ្នែកសំខាន់នៃការអប់រំទូទៅ និងវិជ្ជាជីវៈ ព្រមទាំងអនុញ្ញាតឱ្យមានគម្រោងជាច្រើនជួយជំរុញការអប់រំស្ទែម តាមរយៈការសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលស្ទែមនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យនានា
- ការអប់រំស្ទែមត្រូវបានដាក់បញ្ចូល និងអនុវត្តនៅតាមសាលារៀនសាធារណៈ និងឯកជនមួយចំនួន រួមមានការរៀបចំបន្ទប់ពិសោធន៍ស្ទែម ( STEM Labs ) និងការរៀនបែបគម្រោង ( Project-Based Learning ) និងការបណ្តុះបណ្តាលគ្រូអប់រំស្ទែម
- ការចូលរួមពីដៃគូអភិវឌ្ឍន៍មានដូចជា ADB, WB, USAID, JICA, KOICA និងអង្គការអន្តរជាតិជាច្រើនទៀតបានជួយឧបត្ថម្ភគម្រោងអប់រំស្ទែមនៅកម្ពុជា។ បន្ថែមលើនេះ សហគ្រាសឯកជនដូចជា Smart Axiata ធនាគារ Prasac បានជួយឧបត្ថម្ភការប្រកួតស្ទែម ( STEM Competitions ) និងសាកលវិទ្យាល័យ។

ទោះបីជាយ៉ាងនេះក្តី ក៏ការអប់រំស្ទែមនៅមានបញ្ហាប្រឈម ដូចជាកង្វះខាតគ្រូបង្រៀនដែលមានជំនាញស្ទែមជាន់ខ្ពស់ សម្ភារ និងមូលដ្ឋានគ្រឹះ នៅមិនទាន់មានគ្រប់គ្រាន់ និងនៅមានគម្លាតរវាងទីក្រុង និងជនបទនៅឡើយ។ ដូចនេះ កម្ពុជាត្រូវបន្តការពង្រឹងការអប់រំស្ទែម ដើម្បីត្រៀមសម្រាប់អនាគតអ្នកជំនាន់ក្រោយ សម្រាប់សេដ្ឋកិច្ចឌីជីថល និងឧស្សាហកម្ម ៥.០។

## ២-ក្របខណ្ឌការអប់រំស្ទែមនៅកម្ពុជា

### ២.១- គោលបំណងនៃការអប់រំស្ទែមនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវចក្ខុវិស័យដ៏មោះមុត និងឆ្ពោះទៅមុខ ដើម្បីប្រែក្លាយប្រទេសជាតិទៅជា**ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០** និងជា**ប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០**។ ដើម្បីសម្រេចបាននូវគោលបំណងដ៏មានមហិច្ឆតានេះ កម្ពុជាត្រូវធ្វើការវិនិយោគជាយុទ្ធសាស្ត្រលើការអភិវឌ្ឍមូលធនមនុស្ស ដោយផ្តោតលើការអប់រំ **ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា** ជាចាំបាច់។ ស្ទែមត្រូវបានទទួលស្គាល់យ៉ាងទូលំ

ទូលាយថាជាកាតាលីករសម្រាប់ការច្នៃប្រឌិត វឌ្ឍនភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយនិរន្តរភាព។ ក្នុងបរិបទនេះ គោលបំណងនៃការអប់រំស្ទែមនៅកម្ពុជាគឺមិនមែនគ្រាន់តែបង្រៀនវិទ្យាសាស្ត្រ ឬគណិតវិទ្យាជាមុខវិជ្ជាដាច់ដោយឡែកប៉ុណ្ណោះទេ តែត្រូវបង្កើតប្រព័ន្ធអប់រំរួមបញ្ចូលគ្នា និងទិសដៅអនាគត ដែលរៀបចំយុវជនកម្ពុជាឱ្យរីកចម្រើនក្នុងសេដ្ឋកិច្ចពិភពលោកដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស។

## ២.២- គោលដៅនៃការអប់រំស្ទែមនៅកម្ពុជា

ដើម្បីឆ្លើយតបទៅនឹងគោលបំណងរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា យើងមានគោលដៅមួយចំនួនដូចខាងក្រោម៖

### ក. សម្រាប់សិស្ស

- អភិវឌ្ឍអក្ខរកម្មវិទ្យាសាស្ត្រ និងគណិតវិទ្យា
- លើកកម្ពស់ជំនាញដោះស្រាយបញ្ហា ការគិតស៊ីជម្រៅ និងបែបច្នៃប្រឌិត
- ជំរុញការច្នៃប្រឌិត បង្កើតថ្មី និងការចង់ចេះ ចង់ដឹង ចង់ឃើញ
- រៀបចំសិស្សសម្រាប់អាជីពនាពេលអនាគត
- លើកកម្ពស់អក្ខរកម្មឌីជីថល និងភាពស្ទាត់ជំនាញផ្នែកបច្ចេកវិទ្យា
- លើកទឹកចិត្តឱ្យមានកិច្ចសហការ និងទំនាក់ទំនង

### ខ. សម្រាប់គ្រូ

- ពង្រឹងចំណេះដឹងលើខ្លឹមសារនៃការអប់រំស្ទែម
- កែលម្អជំនាញគរុកោសល្យក្នុងការអប់រំស្ទែម
- ជំរុញការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) លើការអប់រំស្ទែម
- ការបញ្ចូល ICT និងឧបករណ៍ឌីជីថលក្នុងការបង្រៀន
- ជំរុញវប្បធម៌នៃការច្នៃប្រឌិតក្នុងការបង្រៀន
- ពង្រឹងកិច្ចសហការ និងការចែករំលែកបទពិសោធន៍ និងចំណេះដឹងនៃការអប់រំស្ទែម។

### គ. សម្រាប់សាលារៀន

- រៀបចំហេដ្ឋារចនាសម្ព័ន្ធអប់រំស្ទែមគ្រប់គ្រាន់
- រៀបចំក្លឹបសិក្សាអប់រំស្ទែម និងសកម្មភាពក្រៅកម្មវិធីសិក្សា
- លើកកម្ពស់ការបង្រៀនស្ទែមបែបអន្តរមុខវិជ្ជា
- ពង្រឹងភាពជាអ្នកដឹកនាំសាលារៀន និងសមត្ថភាពរៀបចំផែនការអភិវឌ្ឍការអប់រំស្ទែម
- បង្កើតយុទ្ធសាស្ត្រអប់រំស្ទែមថ្នាក់ជាតិ
- ជំរុញភាពជាដៃគូពហុភាគី ប្រមូលធនធាន វិនិយោគ ស្រាវជ្រាវ និងច្នៃប្រឌិតក្នុងការអប់រំស្ទែម
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមពីសហគមន៍

- ជានាបាននូវសមធម៌ក្នុងការអប់រំស្ទែម និងនិរន្តរភាព។

### ឃ. កម្មវិធីអប់រំស្ទែម

- រៀបចំ និងអនុវត្តកម្មវិធីសិក្សាអប់រំស្ទែមតាមស្ថានភាពជាក់ស្តែង
- ពង្រឹងការបង្រៀនរួមបញ្ចូលតាមបែបអន្តរមុខវិជ្ជា បញ្ចូលបច្ចេកវិទ្យាថ្មីៗ និងឆ្លើយតបនឹងយេនឌ័រ
- បង្កើតគន្លងអាជីពស្ទែមសម្រាប់សិស្សត្រៀមបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា
- ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អកម្មវិធីអប់រំស្ទែមជាប្រចាំ។

## ៣- ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន

### ៣.១- គោលបំណង

ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមានគោលបំណងៈ

- ណែនាំគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនឱ្យបញ្ចូលការបង្រៀនបែបអន្តរមុខវិជ្ជាស្ទែម
- គាំទ្រសាលារៀនដើម្បីអនុវត្តការអប់រំស្ទែមប្រកបដោយប្រសិទ្ធភាព
- ពង្រឹងសមត្ថភាពរបស់សិស្សក្នុងការអនុវត្តស្ទែម និងអភិវឌ្ឍបំណិនសតវត្សទី២១ ព្រមទាំងជួយសិស្សឱ្យយល់ដឹងពីទំនាក់ទំនងរវាងការសិក្សានៅសាលារៀន និងការរស់នៅក្នុងជីវិតជាក់ស្តែង ដែលអាចឱ្យសិស្សជ្រើសរើសអាជីពសម្រាប់អនាគតរបស់ពួកគេ។

### ៣.២- សមាសភាគ

សមាសភាគក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមានចំនួន៥ រួមមាន ១. លទ្ធផលសិក្សារបស់សិស្ស ២.ការបង្រៀននិងរៀន ៣. អភិបាលកិច្ចសាលារៀន ៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង៥. ការចូលរួមរបស់សហគមន៍។ សមាសភាគស្ទែមនីមួយៗមានសមាសភាគរង ហើយសមាសភាគរងមានបែងចែកជាប្រធានបទបន្ថែមទៀត ដូចក្នុងតារាងទី៣។

**តារាងទី 3៖ សេចក្តីសង្ខេបសមាសភាគ សមាសភាគរង និងប្រធានបទនៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន**

| ល.រ | សមាសភាគ | ល.រ | សមាសភាគរង | ល.រ | ប្រធានបទ |
|---|---|---|---|---|---|
| ១ | លទ្ធផលសិក្សារបស់សិស្ស | ១.១ | ការប្រមូលសិស្សឱ្យចូលរៀន | ១.១.១ | ការចុះឈ្មោះចូលរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.១.២ | ការចុះឈ្មោះចូលរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | ១.២ | ការរក្សាសិស្សបានគង់វង្សក្នុងសាលារៀន | ១.២.១ | ការមិនបន្តរៀនរបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.២.២ | ការមិនបន្តរៀនរបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |

| | | | | | |
|---|---|---|---|---|---|
| | | ១.៣ | លទ្ធផលសិក្សា | ១.៣.១ | លទ្ធផលសិក្សារបស់សិស្សស្រីក្នុងបណ្តុំវិទ្យាសាស្ត្រ |
| | | | | ១.៣.២ | លទ្ធផលសិក្សារបស់សិស្សប្រុសក្នុងបណ្តុំវិទ្យាសាស្ត្រ |
| ២ | ការបង្រៀន និងរៀន | ២.១ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ២.១.១ | លទ្ធភាពទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| | | | | ២.១.២ | ខ្លឹមសារបណ្តុះបណ្តាល |
| | | | | ២.១.៣ | ប្រធានបទពិសេស |
| | | | | ២.១.៤ | គុណភាព |
| | | | | ២.១.៥ | ការឆ្លើយតបនឹងយេនឌ័រ |
| | | ២.២ | បំណិនឌីជីថល | ២.២.១ | បំណិនឌីជីថលសម្រាប់គ្រូបង្រៀនស្ទែម |
| | | ២.៣ | ការពង្រឹងកម្មវិធីសិក្សា | ២.៣.១ | សម្ភារគាំទ្រ |
| | | | | ២.៣.២ | ការបញ្ចូលខ្លឹមសារកម្មវិធីសិក្សាស្ទែម |
| | | | | ២.៣.៣ | បទពិសោធន៍រៀនស្ទែមជាក់ស្តែង |
| | | | | ២.៣.៤ | ការសម្របតាមសមត្ថភាពសិស្ស |
| | | ២.៤ | ការបញ្ចូលបច្ចេកវិទ្យា | ២.៤.១ | បច្ចេកវិទ្យានៅក្នុងថ្នាក់រៀន |
| | | | | ២.៤.២ | ធនធានឌីជីថល |
| | | | | ២.៤.៣ | បច្ចេកវិទ្យាអប់រំ |
| | | ២.៥ | ការជួយគាំទ្រសិស្ស | ២.៥.១ | ការរៀបចំសៀវភៅកិច្ចការផ្ទះ |
| | | | | ២.៥.២ | ការបំប៉នសិស្សក្រៅម៉ោងសិក្សា |
| | | ២.៦ | ការផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ | ២.៦.១ | បរិបទជីវភាពរស់នៅ |
| | | | | ២.៦.២ | ការយល់ដឹងអាជីពស្ទែមក្នុង និងក្រៅថ្នាក់រៀន |
| | | ២.៧ | វង្វាយតម្លៃ | ២.៧.១ | វិធីសាស្ត្រវង្វាយតម្លៃ |
| | | | | ២.៧.២ | លក្ខណៈវិនិច្ឆ័យនៃវង្វាយតម្លៃ |
| | | | | ២.៧.៣ | ការឆ្លុះបញ្ចាំង និងព័ត៌មានត្រឡប់ |
| | | | | ២.៧.៤ | ការធ្វើបទបង្ហាញរបស់សិស្ស |
| | | | | ២.៧.៥ | ការវាយតម្លៃតាមអេឡិចត្រូនិក |
| | | ២.៨ | ការធ្វើអធិការកិច្ចផ្ទៃក្នុង | ២.៨.១ | ការសង្កេតថ្នាក់រៀន |
| | | | | ២.៨.២ | ការប្រឹក្សា |
| | | | | ២.៨.៣ | ការរៀបចំថ្នាក់និទស្សន៍ |
| | | ២.៩ | សហគមន៍សិក្សាវិជ្ជាជីវៈ | ២.៩.១ | សហគមន៍វិជ្ជាជីវៈ |
| | | ២.១០ | ការបង្រៀន | ២.១០.១ | ការបង្រៀនក្នុងថ្នាក់រៀន |
| | | | | ២.១០.២ | ការអនុវត្តការបង្រៀនតាមបែបទំនើប |
| | | | | ២.១០.៣ | គោលវិធីអន្តរមុខវិជ្ជា |

| | | | | | |
|---|---|---|---|---|---|
| | | | | ២.១០.៤ | ការប្រើប្រាស់ធនធាន |
| | | | | ២.១០.៥ | សកម្មភាពស្ទែមជាក់ស្តែង |
| | | | | ២.១០.៦ | ការឆ្លើយតបនឹងយេនឌ័រ |
| ៣ | អភិបាលកិច្ចសាលារៀន | ៣.១ | វប្បធម៌ស្ទែម | ៣.១.១ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ របៀបវារៈស្ទែម |
| | | | | ៣.១.២ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ ទំនាក់ទំនង |
| | | | | ៣.១.៣ | ឥរិយាបថ និងការប្តេជ្ញាចិត្ត៖ បុគ្គលិក |
| | | ៣.២ | ភាពជាអ្នកដឹកនាំសាលារៀន | ៣.២.១ | ការយល់ដឹង |
| | | | | ៣.២.២ | តួនាទី |
| | | | | ៣.២.៣ | ការគ្រប់គ្រងទីកន្លែងនៅក្នុងសាលារៀន |
| | | | | ៣.២.៤ | ការគ្រប់គ្រងពេលវេលា |
| | | | | ៣.២.៥ | បំណិនឌីជីថល និងបញ្ញាសិប្បនិម្មិត |
| | | | | ៣.២.៦ | ការយល់ដឹងយេនឌ័រ |
| | | ៣.៣ | ការរៀបចំផែនការអភិវឌ្ឍសាលារៀន | ៣.៣.១ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលា |
| | | ៣.៤ | រចនាសម្ព័ន្ធគាំទ្រ | ៣.៤.១ | ក្រុមគ្រូបង្រៀន/សហគមន៍សិក្សាវិជ្ជាជីវៈ |
| | | | | ៣.៤.២ | សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គណៈគ្រប់គ្រង |
| | | | | ៣.៤.៣ | ការប្រឹក្សា ឬការបង្វឹក |
| | | ៣.៥ | ការគ្រប់គ្រងធនធាន | ៣.៥.១ | ការបែងចែកថវិកា |
| | | | | ៣.៥.២ | ភាពជាដៃគូជាមួយអ្នកខាងក្រៅ |
| | | | | ៣.៥.៣ | ការវិភាជថវិកា |
| | | ៣.៦ | ការគ្រប់គ្រងទិន្នន័យ | ៣.៦.១ | ការគ្រប់គ្រងទិន្នន័យ |
| | | | | ៣.៦.២ | ទិន្នន័យតាមក្រុម |
| | | ៣.៧ | ការវាយតម្លៃ | ៣.៧.១ | ការវាយតម្លៃការងារបុគ្គលិក |
| | | | | ៣.៧.២ | ការរៀបចំតេស្តស្តង់ដា |
| | | ៣.៨ | ការទទួលស្គាល់ពីថ្នាក់ជាតិ | ៣.៨.១ | ការវាយតម្លៃសាលាប្រចាំឆ្នាំ |
| ៤ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ៤.១ | សម្ភារបរិក្ខា | ៤.១.១ | សម្ភារបរិក្ខាស្ទែម |
| | | | | ៤.១.២ | សម្ភារបរិក្ខាបច្ចេកវិទ្យា |
| | | | | ៤.១.៣ | បណ្ណាល័យ |
| | | | | ៤.១.៤ | សុវត្ថិភាព |
| | | | | ៤.១.៥ | ការឆ្លើយតបនឹងយេនឌ័រ |
| | | ៤.២ | លទ្ធភាពប្រើប្រាស់ | ៤.២.១ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ពិសោធន៍ ឬបន្ទប់រៀនវិទ្យាសាស្ត្រ |
| | | | | ៤.២.២ | លទ្ធភាពចូលប្រើប្រាស់បន្ទប់ ICT |

| | | | | | |
|---|---|---|---|---|---|
| | | | | ៤.២.៣ | លទ្ធភាពចូលប្រើប្រាស់ប្រកបដោយបរិយាបន្ន |
| | | ៤.៣ | បរិក្ខារ | ៤.៣.១ | បរិក្ខារស្ទែម |
| | | | | ៤.៣.២ | សម្ភារគម្រោងស្ទែម |
| | | | | ៤.៣.៣ | សម្ភារស្ទែមប្រើបានតែម្ដង |
| | | | | ៤.៣.៤ | បរិក្ខារបច្ចេកវិទ្យាអប់រំ |
| | | ៤.៤ | ការភ្ជាប់សេវាសាធារណៈ | ៤.៤.១ | អគ្គិសនី |
| | | | | ៤.៤.២ | អ៊ីនធឺណិត |
| | | | | ៤.៤.៣ | អនាម័យ ការសម្អាត និងទឹក |
| ៥ | ការចូលរួមរបស់សហគមន៍ | ៥.១ | ការចូលរួម និងគាំទ្ររបស់សហគមន៍ | ៥.១.១ | ការប្រាស្រ័យទាក់ទង |
| | | | | ៥.១.២ | ការចូលរួមគាំទ្រ |
| | | | | ៥.១.៣ | គ្រួសារ និងផ្ទត់គំនិតអំពីយេនឌ័រក្នុងស្ទែម |
| | | ៥.២ | ភាពជាដៃគូយុទ្ធសាស្ត្រ | ៥.២.១ | ភាពជាដៃគូស្ទែម |
| | | | | ៥.២.២ | ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធស្ទែម |
| | | | | ៥.២.៣ | ភាពជាដៃគូជាមួយសាលារៀនផ្សេងៗ |
| | | ៥.៣ | សកម្មភាពស្ទែមក្រៅម៉ោងសិក្សា | ៥.៣.១ | ក្លឹបសិក្សាស្ទែមក្រៅសាលារៀន |
| | | | | ៥.៣.២ | ការតាំងពិពណ៌ស្ទែមនៅក្នុងសាលារៀន |
| | | | | ៥.៣.៣ | ព្រឹត្តិការណ៍ស្ទែម ឬការប្រកួតប្រជែងស្ទែម |

## ៣.៣-កម្រិតអភិវឌ្ឍន៍របស់សាលារៀន

ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀននេះ ត្រូវបានរៀបចំដោយផ្អែកលើសមត្ថភាពសាលារៀនផ្សេងៗគ្នាទូទាំងប្រទេសក្នុងគោលបំណងឱ្យក្របខណ្ឌអាចប្រើប្រាស់បានដោយប្រើគោលវិធីពហុកម្រិត និងធ្វើឱ្យសាលារៀននៅតំបន់ផ្សេងៗគ្នា មានលទ្ធភាពអនុវត្តបាន។ ក្របខណ្ឌត្រូវបានរៀបចំឡើងជា៥កម្រិតអភិវឌ្ឍន៍ ដែលកម្រិតសាលារៀនទី១ (ការត្រៀមរៀបចំ) ជាប្រភេទសាលារៀនដែលមានធនធាន និងសមត្ថភាពមានកម្រិត និងកំពុងរៀបចំបញ្ចូលការអនុវត្តស្ទែម។ កម្រិតទី២ (ការយល់ឃើញ) ជាសាលារៀនដែលយល់ឃើញពីការអនុវត្តស្ទែម ប៉ុន្តែនៅខ្វះបទពិសោធន៍។ កម្រិតទី៣ (ការកែលម្អ) ជាសាលារៀនដែលមានធនធាន និងសម្ភារគ្រប់គ្រាន់ដើម្បីអនុវត្តគោលវិធីសរុប។ កម្រិតទី៤ (ការរីកចម្រើន) ជាសាលារៀនដែលមានទំនុកចិត្តក្នុងការអនុវត្តការអប់រំស្ទែម ហើយកម្រិតទី៥ (ការធ្វើជាគំរូ) ជាសាលារៀនដែលបានអនុវត្តការអប់រំស្ទែមពេញលេញ និងគាំទ្រសាលារៀនផ្សេងៗទៀត។

**រូបទី 1៖ កម្រិតអភិវឌ្ឍន៍របស់សាលារៀន**



គោលវិធីពហុកម្រិតនេះ ផ្តល់លទ្ធភាពឱ្យសាលារៀនវាយតម្លៃកម្រិតអភិវឌ្ឍន៍ និងរៀបចំផែនការសកម្មភាព ដែលសមស្របតាមស្ថានភាពសមត្ថភាពរបស់សាលារៀន។ ដើម្បីឱ្យមានប្រសិទ្ធភាព ក្របខណ្ឌស្ទែមនេះត្រូវចាត់ទុកជាមគ្គុទេសក៍ និងជំរុញឱ្យមានការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់លើកម្រិតអភិវឌ្ឍន៍បច្ចុប្បន្ន ហើយក្របខណ្ឌនេះមិនមែនប្រើសម្រាប់**ការវិនិច្ឆ័យ ឬវាយតម្លៃ**នោះទេ ព្រោះការរកឱ្យឃើញកម្រិតអភិវឌ្ឍន៍បច្ចុប្បន្នរបស់សាលារៀន វាអាចមានលម្អៀងឬមិនត្រឹមត្រូវ ជាហេតុធ្វើឱ្យមានការផ្តល់អនុសាសន៍មិនចំគោលដៅសម្រាប់សាលារៀនក្នុងការកែលម្អការអនុវត្តការអប់រំស្ទែមតាមសាលារៀន ដែលផ្ទុយពីគោលបំណងនៃក្របខណ្ឌស្ទែមកម្រិតសាលារៀននេះ។ តារាងទី4 ជាសេចក្តីពិពណ៌នាអំពីកម្រិតអភិវឌ្ឍន៍ទាំង៥ ទៅតាមអ្នកពាក់ព័ន្ធ (រួមមាន៖ សិស្ស គ្រូបង្រៀន គណៈគ្រប់គ្រង និងសហគមន៍)។

### តារាងទី 4៖ សេចក្តីពិពណ៌នាអំពីកម្រិតអភិវឌ្ឍន៍ទាំង៥

| | កម្រិតសាលារៀនទី១ | កម្រិតសាលារៀនទី២ | កម្រិតសាលារៀនទី៣ | កម្រិតសាលារៀនទី៤ | កម្រិតសាលារៀនទី៥ |
|---|---|---|---|---|---|
| | **ការត្រៀមខ្លួន** | **ការឈ្វេងយល់** | **ការកែលម្អ** | **ការរីកចម្រើន** | **ការធ្វើជាគំរូ** |
| **សិស្ស** | សិស្សគ្មានឱកាសសហការប្រើប្រាស់បច្ចេកវិទ្យាឬ ចូលរួមសកម្មភាពអនុវត្តស្ទែមដោយដៃផ្ទាល់។ | សិស្សមានឱកាសសហការម្តងម្កាល ប្រើប្រាស់បច្ចេកវិទ្យា និងសកម្មភាពអនុវត្តស្ទែមដោយដៃផ្ទាល់។ | សិស្សសហការជាញឹកញាប់ ប្រើប្រាស់បច្ចេកវិទ្យា និងសកម្មភាពអនុវត្តស្ទែមដោយដៃផ្ទាល់។ ពួកគេបង្កើតគម្រោងស្ទែម និងចូលរួមព្រឹត្តិការណ៍ស្ទែមម្តងម្កាល។ | សិស្សសហការជាប្រចាំ, ប្រើប្រាស់បច្ចេកវិទ្យា និងសកម្មភាពអនុវត្តស្ទែមដោយដៃផ្ទាល់ និងអន្តរមុខវិជ្ជា។ ក្នុងមេរៀនមុខវិជ្ជាស្ទែម ពួកគេចូលរួមជាទៀងទាត់នៅក្នុងព្រឹត្តិការណ៍ស្ទែម។ | សិស្សប្រើបច្ចេកវិទ្យារៀងរាល់ថ្ងៃនិងតែងតែចូលរួមឬសហការក្នុងគម្រោង និងសកម្មភាពស្ទែមគ្រប់ មុខវិជ្ជា។ ពួកគេតែងតែ ចូលរួមព្រឹត្តិការណ៍ស្ទែម ថ្នាក់តំបន់ ជាតិ និងអន្តរជាតិ។ |
| **គ្រូបង្រៀន** | គ្រូបង្រៀនមិនទាន់យល់ដឹងពីគោលវិធីស្ទែម ជំនាញឌីជីថលនៅមានកម្រិត ប្រើវិធីបង្រៀនបែបបុរាណដោយមិនដាក់បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់ ធ្វើការតែឯងដោយមិនស្វែងរកការគាំទ្រពីអ្នករួមការងារ។ | គ្រូបង្រៀនស្គាល់ពីគោលវិធីស្ទែម ប៉ុន្តែកម្រស្វែងយល់ពីវា ឬ ការអនុវត្តការបង្រៀនតាមបែបទំនើបផ្សេងទៀត។ ពួកគេប្រើបច្ចេកវិទ្យា និងសកម្មភាពអនុវត្តដោយដៃផ្ទាល់ មិនជាប់លាប់ ហើយចែករំលែកបទពិសោធន៍ជាមួយអ្នករួមការងារ ម្តងម្កាល។ | គ្រូបង្រៀអនុវត្តការបង្រៀនតាមបែបទំនើបញឹកញាប់, បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់និងប្រើប្រាស់ធនធានឌីជីថលដែលមានស្រាប់ញឹកញាប់ ការស្វែងរកគោលវិធីអន្តរមុខវិជ្ជា។ ពួកគេចូលរួមសហគមន៍សិក្សាវិជ្ជាជីវៈ ចែករំលែកបទពិសោធន៍ជាមួយអ្នករួមការងារ។ | គ្រូបង្រៀអនុវត្តការបង្រៀនតាមបែបទំនើបញឹកញាប់ បញ្ចូលសកម្មភាពអនុវត្តដោយដៃផ្ទាល់ ស្វែងរកធនធានឌីជីថលថ្មីៗនិងទទួលយកគោលវិធីអន្តរមុខវិជ្ជាក្នុងការបង្រៀន។ ពួកគេជាសមាជិកសកម្មនៃសហគមន៍សិក្សាវិជ្ជាជីវៈ គាំទ្រអ្នកដទៃ និងការចែករំលែកធនធានឬចំណេះដឹង។ | គ្រូបង្រៀនប្រើវិធីបង្រៀនតាមបែបទំនើបជាស្តង់ដាសំដៅទៅរកការបង្រៀនបែបអន្តរមុខវិជ្ជា។ ចូលរួមបង្កើតធនធានឌីជីថលថ្មីៗ ដឹកនាំសហគមន៍សិក្សាវិជ្ជាជីវៈ គាំទ្រអ្នកដទៃ និងការចែករំលែកធនធាន ឬចំណេះដឹង។ |

| | | | | | |
|---|---|---|---|---|---|
| គណៈគ្រប់គ្រង | គណៈគ្រប់គ្រងសាលារៀនមិនទាន់យល់ពីគោលវិធីស្ទែម និងមិនទាន់ដឹងពីតួនាទីក្នុងការលើកកម្ពស់បរិស្ថានអំណោយផលដល់ការអប់រំស្ទែមប្រកបដោយប្រសិទ្ធភាព ។ | គណៈគ្រប់គ្រងសាលារៀនកំពុង កសាងចំណេះដឹងអំពីគោលវិធីស្ទែម ចាប់ផ្តើមដឹងពីតម្រូវការពាក់ព័ន្ធនៅក្នុងសាលារៀននិងតួនាទីក្នុងការដោះស្រាយតម្រូវការទាំងនោះ។ | គណៈគ្រប់គ្រងសាលារៀនយល់ពីគោលវិធីស្ទែម គាំទ្រគ្រូបង្រៀនស្ទែម និងបុរេសកម្មស្វែងរកដំណោះស្រាយបញ្ហាប្រឈមការអនុវត្តស្ទែម នៅក្នុងស្ថានភាពរបស់សាលារៀន។ | គណៈគ្រប់គ្រងសាលារៀនបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបញ្ចូលគោលវិធីស្ទែម និងបុរេសកម្មស្វែងរកធ្វើឱ្យប្រសើរឡើង សមត្ថភាពស្ទែមនៅក្នុងស្ថានភាពសាលារៀន។ | គណៈគ្រប់គ្រងសាលារៀនគាំទ្រគោលវិធីស្ទែម បង្កលក្ខណៈនិងស្វែងរកសកម្មភាពស្ទែម អន្តរសាលារៀន និងជួយគាំទ្រសាលារៀនជិតខាង។ |
| សហគមន៍ | គ្រួសារ និងសមាជិកសហគមន៍មិនបានផ្សារភ្ជាប់ជាមួយសកម្មភាពសាលារៀន។ ពួកគេដឹងតួនាទីអប់រំបរិស្ថានស្ទែមឱ្យមានការរីកចម្រើននៅសាលារៀន។ | គ្រួសារ និងសមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់ស្ទែម និងតួនាទីដែលពួកគេជួយដល់សាលារៀន។ | គ្រួសារ និងសមាជិកសហគមន៍គាំទ្រសាលារៀន ហើយចូលរួមម្តងម្កាលក្នុងសកម្មភាពស្ទែម។ | គ្រួសារ និងសមាជិកសហគមន៍គាំទ្រយ៉ាងសកម្មដល់សាលារៀន ចូលរួមជាទៀងទាត់ក្នុងសកម្មភាពស្ទែម និងផ្តល់ឱកាសមួយចំនួនសម្រាប់ចូលរួមជាបទពិសោធន៍ជាក់ស្តែង។ | គ្រួសារ និងសមាជិកសហគមន៍ប្តេជ្ញាគាំទ្រសាលារៀននិងដើរតួនាទីសំខាន់នៅក្នុងសកម្មភាពឬព្រឹត្តិការណ៍ស្ទែម បង្កើតឱកាសមួយមចំនួនសម្រាប់ចូលរួមជាបទពិសោធន៍ជាក់ស្តែង ។ |

## ៣.៤-ជំហាននៃការអនុវត្ត និងកញ្ចប់ឧបករណ៍ស្ទែម

ការអនុវត្តក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនមាន ៥ ជំហាន ដោយមានកញ្ចប់ឧបករណ៍ស្ទែម ជាជំនួយ ( សូមមើលរូបទី2 )។

**រូបទី 2៖ ជំហានទាំង៥ នៃការអនុវត្តក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន និងកញ្ចប់ឧបករណ៍ស្ទែម**



## ជំហានទី១៖ ការបង្កើតគណៈកម្មការអនុវត្តសកម្មភាពអប់រំស្ទែម

## ឧបករណ៍ណែនាំ៖ ការបង្កើតគណៈកម្មការអនុវត្តសកម្មភាពអប់រំស្ទែម




ជំហានទី១ក្នុងដំណើរការ៥ជំហាននៃរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនគឺការបង្កើតក្រុមអនុវត្តសកម្មភាពស្ទែម។ ក្រុមអនុវត្តសកម្មភាពស្ទែមនេះមានសមាជិកបង្គោលដែលទទួលខុសត្រូវក្នុងការណែនាំសាលារៀនតាមរយៈដំណើរការ ៥ជំហាន និងសមាជិកគាំទ្រ ដែលមានតួនាទីគាំទ្រសមាជិកបង្គោល។ ឧបករណ៍ណែនាំអំពីក្រុមអនុវត្តសកម្មភាពស្ទែមជួយគណៈគ្រប់គ្រងសាលារៀនក្នុងការចាត់តាំងសមាជិកដែលមានសក្ដានុពល និងសង្ខេបពីទំនួលខុសត្រូវ។ សាលារៀននីមួយៗមានស្វ័យភាពក្នុងការជ្រើសរើសសមាជិកក្រុមអនុវត្តសកម្មភាពស្ទែមរបស់ខ្លួន ដោយផ្អែកលើស្ថានភាពសាលារៀនជាក់ស្ដែង។ មុននឹងការជ្រើសរើសសមាជិក គណៈគ្រប់គ្រងសាលារៀនត្រូវយល់ដឹងពីលំនាំនៃដំណើរការ និងសមាសភាគស្ទែម (សូមមើលឧបសម្ព័ន្ធ ក) ដើម្បីធានាបានកម្រិតជំនាញ និងចំណេះដឹងដ៏សមស្របមួយរបស់មាជិកក្រុម។ ជាក់ស្ដែង ក្រុមអនុវត្តសកម្មភាពស្ទែមត្រូវជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីតាមដានវឌ្ឍនភាព ហើយគួរតែជាបុគ្គលដែលយល់ពីតួនាទីរបស់ស្ទែមនាពេលអនាគត និងជាអ្នកដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ខ្ជាប់ខ្ជួន ឧស្សាហ៍ព្យាយាម និងមានសមត្ថភាពគ្រប់គ្រងការអប់រំស្ទែម។

**រូបទី 3៖ សេចក្ដីសង្ខេបនៃសមាជិក និងតួនាទីរបស់ក្រុមអនុវត្តសកម្មភាពស្ទែម**



# ជំហានទី២៖ ការធ្វើស្វ័យវាយតម្លៃ និងការកំណត់កម្រិតអភិវឌ្ឍន៍តាមសមាសភាគ

## ឧបករណ៍ស្ទែម៖ ឧបករណ៍ស្វ័យវាយតម្លៃ




ជំហានទី២ នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ពាក់ព័ន្ធនឹងការឆ្លុះបញ្ចាំងយ៉ាងហ្មត់ចត់លើការអនុវត្តស្ទែមនៅសាលារៀននាពេលបច្ចុប្បន្ន ដើម្បីអាចកំណត់កម្រិតអភិវឌ្ឍន៍បច្ចុប្បន្នរបស់សាលារៀន។ ឧបករណ៍ស្វ័យវាយតម្លៃសម្រាប់សមាសភាគទាំងប្រាំ (សូមមើលឧបសម្ព័ន្ធ ក ជួយឱ្យក្រុមអនុវត្តសកម្មភាពស្ទែមក្នុងការពិនិត្យលើសមាសភាគនីមួយៗ។ សមាជិកក្រុមអនុវត្តសកម្មភាពស្ទែម ត្រូវចែករំលែកទំនួលខុសត្រូវក្នុងការដឹកនាំការឆ្លុះបញ្ចាំងសមាសភាគទាំងនេះ (សមាសភាគ ១ ឬ ២ ដែលត្រូវប្រគល់ឱ្យសមាជិកនីមួយៗ) ដើម្បីជៀសវាងកុំឱ្យសមាជិកធ្វើការច្រើនពេក។ ការឆ្លុះបញ្ចាំងដោយភាពស្មោះត្រង់ គឺមានសារៈសំខាន់សម្រាប់សាលារៀន ដើម្បីទទួលបានអត្ថប្រយោជន៍ពីដំណើរការនៃក្របខណ្ឌនេះ។ ការកំណត់កម្រិតអភិវឌ្ឍន៍មិនបានសមស្រប ក៏នាំឱ្យមានអនុសាសន៍មិនបានត្រឹមត្រូវ ដែលធ្វើឱ្យរារាំងដល់ការកែលម្អសាលារៀនក្នុងការអប់រំស្ទែម។

| កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) |
| --- |
| កម្រិតអភិវឌ្ឍន៍តាមសមាសភាគសម្រាប់សមាសភាគជាក់លាក់ណាមួយអាស្រ័យលើកម្រិតសមត្ថភាពស្ទែមពីកម្រិតសាលារៀនទី១ ដល់ ៥។ |

ឧបករណ៍ស្វ័យវាយតម្លៃទាំងប្រាំ មានសំណួរស្ទាប់ស្ទង់ជាស៊េរី តាមសមាសភាគរង និងប្រធានបទនៃសមាសភាគនីមួយៗ។ សំណួរនីមួយៗមានជម្រើសចម្លើយចំនួន ៥ ដែលរៀបតាមលំដាប់កម្រិតអភិវឌ្ឍន៍កើនពីកម្រិតសាលារៀន ទី១ ដល់ ៥ ។ សមាជិកអនុវត្តសកម្មភាពស្ទែម ជ្រើសរើសចម្លើយមួយសម្រាប់សំណួរនីមួយៗដែលសមស្របបំផុតទៅនឹងស្ថានភាពនៅសាលារៀនដោយកត់ត្រានៅក្នុងតារាងនៃឧបករណ៍ស្វ័យវាយតម្លៃ។ ក្រោយពីបានឆ្លើយសំណួរទាំងអស់ត្រូវបូកសរុបលទ្ធផលសម្រាប់កម្រិតអភិវឌ្ឍន៍នីមួយៗតាមសមាសភាគនីមួយៗ។ ចំណុចខ្លាំង និងចំណុចសម្រាប់អភិវឌ្ឍត្រូវបានកំណត់ផងដែរនៅក្នុងសមាសភាគនីមួយៗ តាមរយៈការពិនិត្យលើសមាសភាគរងដែលមានតម្លៃខ្ពស់ជាង ឬទាបជាងកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDL) សូមមើលឧបសម្ព័ន្ធ ក។

## ជំហានទី៣៖ ការពិនិត្យឡើងវិញ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប (ODL) និងការកំណត់គោលដៅ

## ឧបករណ៍ស្ទែម៖ ឧបករណ៍ពិនិត្យឡើងវិញ និងឧបករណ៍ពិនិត្យកំណត់គោលដៅ

ជំហានទី៣ នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនពាក់ព័ន្ធនឹងការពិនិត្យឡើងវិញនូវការអនុវត្តរបស់សាលារៀននៅក្នុងសមាសភាគស្ទែមទាំង៥។ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅជួយសម្រួលដល់ការពិនិត្យឡើងវិញនេះ ដោយកត់ត្រាការអនុវត្តរបស់សាលារៀន ដូចដែលបានរកឃើញនៅក្នុងជំហានទី២ សូមមើលតារាងទី5។ ការគណនារកតម្លៃមធ្យមនៃតម្លៃកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDLs) នៃសមាសភាគទាំង៥ ត្រូវបានគេហៅថា "កម្រិតអភិវឌ្ឍន៍សរុប (ODL)" របស់សាលារៀន។




**តារាងទី 5៖ ការកំណត់កម្រិតអភិវឌ្ឍន៍សរុប(ODL)***

| ល.រ | សមាសភាគស្ទែម | កម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDLs) * |
|---|---|---|
| 1 | លទ្ធផលការសិក្សារបស់សិស្ស | |
| 2 | ការបង្រៀន និងរៀន | |
| 3 | អភិបាលកិច្ចសាលារៀន | |
| 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | |
| 5 | ការចូលរួមរបស់សហគមន៍ | |
| | **តម្លៃសរុប** | |
| | **កម្រិតអភិវឌ្ឍន៍សរុប(ODL) = តម្លៃសរុប /5** | |

*តម្លៃនៅតារាងនេះយកពីលទ្ធផលចេញពីជំហានទី២៖ ឧបករណ៍ស្វ័យវាយតម្លៃ

| កម្រិតអភិវឌ្ឍន៍សរុប (ODL) |
|---|
| បង្ហាញពីកម្រិតអភិវឌ្ឍន៍របស់សាលារៀនតាមសមាសភាគស្ទែមទាំង៥ ដោយអាស្រ័យលើកម្រិតសមត្ថភាពស្ទែមពីកម្រិតសាលារៀនទី១ ដល់ ៥។ |

ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ជួយឱ្យក្រុមអនុវត្តសកម្មភាពស្ទែមក្នុងការប្រៀបធៀបការអនុវត្តនៅក្នុងសមាសភាគនីមួយៗ (ដោយពិចារណាលើកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDLs)) ដើម្បីកំណត់សមាសភាគដែលដំណើរការខ្សោយជាង ឬខ្លាំងជាងកម្រិតអភិវឌ្ឍន៍សរុប (ODL)។ ដំណើរការនេះជួយកំណត់យ៉ាងច្បាស់នូវភាពខ្លាំង និងចំណុចខ្សោយ (សូមមើលតារាងទី6)។

**តារាងទី 6៖ សេចក្តីសង្ខេបនៃកម្រិតអភិវឌ្ឍន៍សរុប(ODL) និងការកំណត់សមាសភាពខ្លាំងនិងខ្សោយ**

| តម្លៃ ODL | ល.រ | សមាសភាគ | តម្លៃ DDL | ជួរឈរ ក | ជួរឈរ ខ | ជួរឈរ គ |
|---|---|---|---|---|---|---|
| | | | | សមាគសភាគ ស្ទែមខ្សោយ ✓ DDL ទាបជាង ODL | សមាគសភាគ ស្ទែមត្រូវគ្នានឹង ODL ✓ DDL ស្មើ ODL | សមាគសភាគ ស្ទែមខ្លាំង ✓ DDL ធំជាង ODL |
| តម្លៃ ODL ______ | 1 | លទ្ធផលការសិក្សារបស់សិស្ស | | | | |
| | 2 | ការបង្រៀន និងរៀន | | | | |
| | 3 | អភិបាលកិច្ចសាលារៀន | | | | |
| | 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | | | | |
| | 5 | ការចូលរួមរបស់សហគមន៍ | | | | |

ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ណែនាំក្រុមអនុវត្តសកម្មភាពស្ទែមក្នុងការកំណត់គោលដៅសមស្របសម្រាប់ឆ្នាំខាងមុខ ហើយកំណត់ថាតើផែនការសកម្មភាពស្ទែមណាដែលគួរអនុវត្តក្នុងជំហានទី៤ ដើម្បីឆ្ពោះទៅរកគោលដៅនេះ។ សាលារៀនមានសិទ្ធិក្នុងការជ្រើសរើស៖

១. ជម្រើសទី១៖ ពង្រឹងសមាសភាគទាំងឡាយណា ក្នុងចំណោមសមាសភាគទាំង ៥ ដែលបានកំណត់ថាខ្សោយនៅក្នុងតារាងទី៦ ដើម្បីឱ្យសមាសភាគទាំង៥ មានកម្រិតអភិវឌ្ឍន៍ស្មើគ្នា នាឆ្នាំខាងមុខ។

២. ជម្រើសទី២៖ ពង្រឹងសមាសភាគយ៉ាងហោចណាស់៣ ដើម្បីសម្រេចបាននូវកម្រិតអភិវឌ្ឍន៍បន្ទាប់។

ការសម្រេចបាននូវជម្រើសមួយក្នុងចំណោមជម្រើសទាំងនេះ ត្រូវបានចាត់ទុកថារីកចម្រើនលើដំណើររបស់សាលារៀនឆ្ពោះទៅរកការកែលម្អការអប់រំស្ទែម។ ផ្នែកចុងក្រោយនៃឧបករណ៍នេះ ជួយឱ្យក្រុមអនុវត្តសកម្មភាពស្ទែមកំណត់យ៉ាងច្បាស់នូវគោលដៅរបស់ពួកគាត់សម្រាប់ឆ្នាំសិក្សាខាងមុខនេះ ហើយជ្រើសរើសផែនការសកម្មភាពស្ទែមដែលពួកគាត់គួរអនុវត្តតាមនៅជំហានទី៤ ដើម្បីសម្រេចបានគោលដៅ (សូមមើលឧបសម្ព័ន្ធ ក)។

## ជំហានទី៤៖ ការអនុវត្តផែនការសកម្មភាពស្ទែម
## ឧបករណ៍ស្ទែម៖ ផែនការសកម្មភាពស្ទែម




ជំហានទី ៤ នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពស្ទែមនៅសាលារៀន ដែលស្របតាមតម្រូវការ និងកម្រិតនៃការអភិវឌ្ឍន៍បច្ចុប្បន្នរបស់សាលារៀន។ ផែនការសកម្មភាពរបស់ក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនផ្តល់នូវជំហានជាក់ស្តែងសម្រាប់ការលើកកម្ពស់ការអប់រំស្ទែមតាមសមាសភាគនីមួយៗនៃសមាសភាគទាំង៥។ ផែនការសកម្មភាពទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើកម្រិតអភិវឌ្ឍន៍ ដែលអាចឱ្យសាលារៀនអនុវត្តតាមផែនការ។ ទោះបីជាមានការប្រឈមខ្លះៗ ដូចជាសម្ភារបរិក្ខារ ឬថវិកាមានកម្រិតក៏ដោយ សាលារៀនត្រូវបានលើកទឹកចិត្តឱ្យបន្តសកម្មភាពដែលអាចធ្វើទៅបាន និងអាចលុបចោលនូវអ្វីដែលហួសពីលទ្ធភាពរបស់សាលារៀន។ ការកំណត់ចំណុចដៅនៅក្នុងផែនការត្រូវមានលក្ខណៈសមស្របតាមកម្រិតអភិវឌ្ឍន៍ដែលជារង្វាស់នៃវឌ្ឍនភាព។ ការចាប់ផ្តើមធ្វើផែនការ ត្រូវត្រឡប់ទៅមើលឧបករណ៍ណែនាំក្រុមអនុវត្តសកម្មភាពស្ទែម ជំហានទី៣៖ ឧបករណ៍ពិនិត្យឡើងវិញ និងកំណត់គោលដៅ ដើម្បីកំណត់ឱ្យបានត្រឹមត្រូវថាតើផែនការសកម្មភាពស្ទែមមួយណាដែលត្រូវអនុវត្តតាមចំពោះសមាសភាគនីមួយៗ។ ឧបករណ៍នេះប្រាប់ពីធនធានសំខាន់ៗដើម្បីជួយក្រុមអនុវត្តសកម្មភាពស្ទែមក្នុងការអនុវត្តផែនការទាំងនេះ (សូមមើលឧបសម្ព័ន្ធ ក)។

## ជំហានទី៥៖ ការត្រួតពិនិត្យវឌ្ឍនភាព និងការអនុវត្តឡើងវិញប្រចាំឆ្នាំ
## ឧបករណ៍ស្ទែម៖ ឧបករណ៍តាមដានវឌ្ឍនភាពក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន




ជំហានទី៥ នៃក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនពាក់ ព័ន្ធនឹងការពិនិត្យមើលវឌ្ឍនភាពពាក់កណ្តាលឆ្នាំ និងវឌ្ឍនភាពចុងឆ្នាំ ជារួមការឆ្លុះបញ្ចាំងសមាសភាគស្ទែមទាំង៥ និងការជ្រើសរើសគោលដៅសម្រាប់ឆ្នាំបន្ទាប់។ ឧបករណ៍តាមដានវឌ្ឍនភាពក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀនណែនាំក្រុមអនុវត្តសកម្មភាពស្ទែមឱ្យពិនិត្យឡើងវិញនៅចុងឆ្នាំតាមលំនាំជំហានទី២ និងទី៣ នៃលំនាំដំណើរការក្របខណ្ឌអប់រំស្ទែមកម្រិតសាលារៀន ដែលបង្កើតបានជាវដ្តប្រចាំឆ្នាំ។ ឧបករណ៍នេះជួយក្រុមអនុវត្តសកម្មភាពស្ទែម កំណត់តម្លៃកម្រិតអភិវឌ្ឍន៍តាម

សមាសភាគ (DDLs) និងកម្រិតអភិវឌ្ឍន៍សរុប (ODL) នៅចុងឆ្នាំ ហើយពិនិត្យមើលវឌ្ឍនភាពដោយប្រៀបធៀបទៅនឹងតម្លៃកម្រិតអភិវឌ្ឍន៍តាមសមាសភាគ (DDLs) និងកម្រិតអភិវឌ្ឍន៍សរុប (ODL) ពីមុន (សូមមើលតារាងទី7)។ ការប្រៀបធៀបនេះជាបច្ច័យមួយឱ្យក្រុមអនុវត្តសកម្មភាពស្ទែម វាយតម្លៃថាតើគោលដៅដែលបានកំណត់នៅដើមឆ្នាំត្រូវបានសម្រេចដែរឬទេ និងកំណត់គោលដៅសមស្របសម្រាប់ឆ្នាំខាងមុខ។ ឧបករណ៍នៅជំហានទី៥ កត់ត្រាវឌ្ឍនភាពដែលបានធ្វើឡើងក្នុងរយៈពេលជាច្រើនឆ្នាំផងដែរ (សូមមើលឧបសម្ព័ន្ធ ក)។

**តារាងទី 7៖ ការប្រៀបធៀបកម្រិតអភិវឌ្ឍន៍របស់សមាសភាគនីមួយៗ រវាងដើមឆ្នាំនិងចុងឆ្នាំ**

| ល.រ | សមាសភាគ | សមាសភាគត្រូវផ្តោត | តម្លៃ DDL នៅដើមឆ្នាំ | តម្លៃ DDL នៅចុងឆ្នាំ | តើសមាសភាគណាមួយមានការរីកចម្រើន? |
|---|---|---|---|---|---|
| 1 | លទ្ធផលការសិក្សារបស់សិស្ស | ☐ | | | ☐ |
| 2 | ការបង្រៀន និងរៀន | ☐ | | | ☐ |
| 3 | អភិបាលកិច្ចសាលារៀន | ☐ | | | ☐ |
| 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ☐ | | | ☐ |
| 5 | ការចូលរួមរបស់សហគមន៍ | ☐ | | | ☐ |
| | | សរុប | | | |
| | | **តម្លៃ ODL**(តម្លៃមធ្យម=តម្លៃសរុប/5) | | | |

**តារាងទី 8៖ ការតាមដានវឌ្ឍនភាពផ្អែកលើតម្លៃកម្រិតអភិវឌ្ឍន៍សរុប (ODL) ដែលបានវាយតម្លៃជាច្រើនដង**

| ពេលវេលា | កម្រិតអភិវឌ្ឍន៍សរុប (ODL) |
|---|---|
| ពេលដើម = 0 | |
| ចុងឆ្នាំទី១ | |
| ចុងឆ្នាំទី២ | |
| ចុងឆ្នាំទី៣ | |
| ចុងឆ្នាំទី៤ | |